ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# អ្នកដឹកនាំព្រះ
# វិហារមកជួបព្រះ
# យេស៊ូ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

ថ្ងៃមួយព្រះយេស៊ូបានយាងទៅព្រះវិហារ ព្រះអង្គបានទត
ឃើញថា មនុស្សបានផ្តល់តម្លៃដល់ដំណាក់របស់ព្រះជា
ម្ចាស់នោះទេ។ ពួកគេបានយកកន្លែងថ្វាយបង្គំព្រះជាម្ចាស់
ធ្វើជាកន្លែងលក់ដូ នឹងប្តូរប្រាក់នៅក្នុងព្រះវិហារ។



ព្រះយេស៊ូបានយកខ្សែមកធ្វើជារំពាត់ ហើយដេញពួកគេចេញពីព្រះវិហារ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ “ឆាប់យករបស់ទាំងអស់នេះចេញទៅ កុំធ្វើអោយដំណាក់របស់បិតាខ្ញុំទៅជារោងចោទ្បើយ” ។ ព្រះយេស៊ូទ្រង់ស្រឡាញ់ដំណាក់របស់បិតាទ្រង់។





អ្នកដឹកនាំម្នាក់ក៏ចូលមក
រកព្រះយេស៊ូ ហើយ
ទាមទារឲ្យព្រះអង្គបង្ហាញ
ទីសម្គាល់បញ្ជាក់ថា ព្រះ
អង្គមានសិទ្ធក្នុងបណ្តេញ
ពួកគេចេញពីព្រះវិហារ។
ព្រះយេស៊ូមានបន្ទូលថា
៖ “ចូររុះព្រះវិហារនេះ
ចោលទៅ ខ្ញុំនឹងសង់
ឡើងវិញក្នុងរវាងបីថ្ងៃ”។
វាមិនអាចទៅរួចនោះទេ!
ព្រះវិហារនោះគេចំណាយ
ពេល៤៦ ឆ្នាំ ដើម្បីសាង
សង់។

ប៉ុន្តែព្រះយេស៊ូចង់មានបន្ទូលពីព្រះកាយ
របស់ព្រះអង្គឯណោះវិញទេ ។ ព្រះកាយ
របស់ព្រះអង្គប្រៀបដូចជាព្រះវិហារដែលព្រះ
ជាម្ចាស់គង់នៅ។ ទោះបីជា
ព្រះយេស៊ូនឹងសុគតនៅលើឈើ
ឆ្កាងក៏ដោយ តែព្រះអង្គជ្រាបថា
ព្រះជាម្ចាស់នឹងប្រោសព្រះអង្គឲ្យរស់
ឡើងវិញក្នុងរយៈពេល៣ថ្ងៃ។





នៅយប់មួយនោះ មាន
អ្នកដឹកនាំក្នុងព្រះវិហារ
ម្នាក់មករកព្រះយេស៊ូ។
លោកបានដឹងថា ព្រះ
យេស៊ូជាព្រះបុត្រាដែល
ព្រះបានចាត់ឲ្យមក។
លោកនីកូដេម បានមកឯ
ព្រះយេស៊ូហើយរៀនមេ
រៀនដ៏អស្ចារ្យពីព្រះអង្គ។



ព្រះយេស៊ូ មានព្រះបន្ទូល
ប្រាប់លោកនីកូដេមថា
មនុស្សត្រូវកើតជាថ្មីសិន
ទើបអាចចូលទៅក្នុងព្រះ
រាជ្យរបស់ព្រះជាម្ចាស់បាន។
លោកនីកូដេម មិនយល់
នោះទេ។ តើមនុស្សធំហើយ
នេះ អាចចូលទៅក្នុងផ្ទៃម្ដា
យហើយកើតម្ដងទៀត
យ៉ាងដូចម្ដេច? លោកជា
អ្នកដឹកនាំសាសនាម្នាក់
លោកមិនយល់ពីរឿងនេះ
សោះ។ តើវាពិតជាមិនទំនង
សោះមែនទេ?



ព្រះយេស៊ូពន្យល់ថា “អ្នក
ដែលកើតពីព្រះវិញ្ញាណ គឺ
មានព្រះវិញ្ញាណនៅក្នុង
ខ្លួន ព្រះវិញ្ញាណរបស់ព្រះ
ជាម្ចាស់ ប្រៀបដូចជាខ្យ
ល់។ មនុស្សមិនអាចឃើញ
ខ្យល់ទេ។ មនុស្សមើលមិន
ឃើញខ្យល់នោះទេ ប៉ុន្តែគេ
មើលអ្វីៗ ដែលត្រូវខ្យល់
បក់មានចលនា”។



ព្រះយេស៊ូបានរំលឹក លោកនីកូដេមអំពី កូនចៅរបស់លោកអ៊ីស្រាអែលដែលបានរអ៊ូរទាំដាក់លោកម៉ូសេ កាលពីជំនាន់មុន។ ពួកគេត្អូញត្អែរថា “យើងគ្មានអាហារ គ្មានទឹក ហើយពួកយើងធុញនឹងនំបុ័ងដែលព្រះប្រទានមកនេះណាស់”។

ព្រះជាម្ចាស់ព្រះពិរោធដោយសារអំពើ
បាបរបស់មនុស្សលោក។ ព្រះអង្គបាន
បញ្ជូនពស់ភ្លើងឲ្យមកលុកលុយកន្លែង
ពួកគែរស់នៅ។ សត្វពស់បានសម្លាប់
ពួកគេអស់ជាច្រើននាក់។





ប្រជាជនបានទូលអង្វរថា ៖ “យើង
ជាមនុស្សមានបាប សូមព្រះអង្គដក
ពស់ភ្លើងនេះចេញទៅ”។ ដូចនេះ
លោកម៉ូសេក៏អធិស្ឋានទូលអង្វរព្រះ
ព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់មិន
បានយកសត្វពស់ចេញឡើយ។



ព្រះជាម្ចាស់បានប្រាប់ម៉ូសេឲ្យធ្វើពស់មួយពីលង្ហិន ហើយដាក់ពស់នោះព្យួរលើបង្គោលខ្ពស់មួយ។ ព្រះជាម្ចាស់មានព្រះបន្ទូលថា ៖ “អ្នកណាដែលត្រូវពស់ចឹក នឹងបានជាឡើងវិញនៅពេលក្រឡេកមើលទៅសត្វពស់លង្ហិននៅលើបង្គោលនោះ”។ លោកម៉ូសេបានធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអស់អ្នកណាដែលសម្លឹងមើលទៅពស់លង្ហិននោះក៏បានជា។


ព្រះយេស៊ូមានព្រះបន្ទូលទៅ
កាន់លោកនីកូដេមថា៖ “កាលនៅ
វាលរហោស្ថាន លោកម៉ូសេបានលើក
ពស់ឡើងយ៉ាងណា បុត្រមនុស្សនឹង
ត្រូវគេលើកឡើងយ៉ាងនោះដែរ”។
ព្រះយេស៊ូមានបន្ទូលអំពីការសុគត
នៅលើឈើឆ្កាងរបស់ព្រះអង្គ
ដើម្បីលោះមនុស្សដែល
មានបាប។


ព្រះយេស៊ូមានបន្ទូលថា៖
“ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក
ខ្លាំងណាស់ ហេតុនេះហើយបានជា
ព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់
ព្រះអង្គមក ដើម្បីអោយអស់អ្នក
ដែលជឿលើព្រះបុត្រា
មានជីវិតអស់កល្បជានិច្ច
គឺមិនអោយគេ
វិនាសឡើយ”។


ការនេះមានន័យថា អ្នកណាក៏
ដោយដែលទទួលជឿព្រះយេស៊ូ
អ្នកនោះនឹងបានកើតជាថ្មីក្នុង
គ្រួសាររបស់ព្រះជាម្ចាស់។

ប្រហែលនៅយប់នោះ លោកនីកូដេម មិនបានក្លាយជាសិស្សរបស់
ព្រះអង្គនោះទេ។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក លោកនីកូដេមបាន
បង្ហាញថា លោកបានជឿទៅលើព្រះយេស៊ូ
ព្រមទាំងបានជួយបញ្ចុះព្រះ
សពរបស់ព្រះអង្គផង។



បន្ទាប់មក ព្រះយេស៊ូនិងសិស្សរបស់ព្រះអង្គ បានធ្វើដំណើរទៅភាគខាងជើង។ ប្រជាជននៅតំបន់ផ្សេងៗ ត្រូវការស្តាប់ព្រះបន្ទូលអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ព្រមទាំងមានឱកាសទទួលជឿព្រះយេស៊ូអ្នកភូមិណាសារ៉ែត ដែលជាព្រះបុត្រានៃព្រះជាម្ចាស់។



អ្នកដឹកនាំព្រះវិហារមកជួបព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

យូហាន ២-៣, ជនគណនា ២១

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្លេ៉ះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣:១៦